ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
~~~***~~~

សាលាដំបូងខេត្តកណ្តាល
សាលក្រមព្រហ្មទណ្ឌលេខៈ **០២១(ឆ)**
ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តកណ្តាល

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងខេត្តកណ្តាល និងប្រកាសជាសាធារណៈនៅសាលាដំបូងខេត្តកណ្តាល នាថ្ងៃទី១៥ ខែមករា ឆ្នាំ២០២០ ដោយមានសមាសភាពដូចតទៅ៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមជំនុំជម្រះនៃសាលាដំបូងខេត្តកណ្តាល

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តខេត្តកណ្តាល

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តខេត្តកណ្តាល

**មេធាវី**

លោក [redacted] និង កញ្ញា [redacted] ជាមេធាវីការពារក្តីឲ្យជនជាប់ចោទ

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខៈ **៣៦៧ អក** ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៩ ដែលមានជនជាប់ចោទ៖

១.ឈ្មោះ [redacted] សុធីរៈ ហៅ **ព្រួញ** ភេទប្រុស អាយុ ៣០ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ កសិករ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូ[redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] ជី (រ) ម្តាយឈ្មោះ [redacted] ព្រីង (រ) ប្រពន្ធឈ្មោះ [redacted] សេរីរ័ត្ន មានកូន ០១ នាក់ ទោសពីមុន គ្មាន ។ (ក្រៅឃុំ)

២.ឈ្មោះ [redacted] **ប៊ុនណាក់** ភេទប្រុស អាយុ ៣៤ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ បុគ្គលិកក្រុមហ៊ុនឯកជន ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិ[redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] ជី (រ) ម្តាយឈ្មោះ [redacted] ព្រីង (រ) ប្រពន្ធឈ្មោះ [redacted] ភារី មានកូន ០២ នាក់ ទោសពីមុន គ្មាន ។ (ក្រៅឃុំ)

៣.ឈ្មោះ [redacted] **អាំងនីវ** ភេទស្រី អាយុ ៣៧ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ កសិករ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិ[redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] ជី (រ) ម្តាយឈ្មោះ [redacted] ព្រីង (រ) ប្តីឈ្មោះ [redacted] សុជា មានកូន ០២ នាក់ ទោសពីមុន គ្មាន ។ (ក្រៅឃុំ)

៤.ឈ្មោះ [redacted] **សុជា ហៅ ទូច** ភេទប្រុស អាយុ ៣៧ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ កសិករ ទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តកណ្តាល និងទីលំនៅបច្ចុប្បន្ននៅភូ[redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] ខេង (រ) ម្តាយឈ្មោះ [redacted] សុខកន (រ) ប្រពន្ធឈ្មោះ [redacted] អាំងនីវ មានកូន ០២ នាក់ ទោសពីមុន គ្មាន ។ (ក្រៅឃុំ)



Scanned with CamScanner
~~~

ពីបទ៖ **ហិង្សាដោយចេតនា** ប្រព្រឹត្តនៅភូមិព្រែក ឃុំត្រើយស្លា ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី ០៩ ខែមីនា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ។

ជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សុខយន** ភេទប្រុស អាយុ ៦១ឆ្នាំ ទីលំនៅសព្វថ្ងៃនៅភូមិពរែកប៉ាន ឃុំត្រើយស្លា ស្រុកស្អាង ខេត្តកណ្តាល ។

ជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សារឿន** ភេទស្រី អាយុ ៦០ឆ្នាំ ទីលំនៅសព្វថ្ងៃនៅភូមិពរែកប៉ាន ឃុំត្រើយស្លា ស្រុកស្អាង ខេត្តកណ្តាល ។

## ដំណើររឿងមានដូចតទៅ

កាលពីថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៩ វេលាម៉ោង ១៣ និង ០០នាទី មានឈ្មោះ [redacted] ព្រីង បាននាំកូនឈ្មោះ [redacted] សុធីរៈ , ឈ្មោះ [redacted] ប៊ុនណាក់ , ឈ្មោះ [redacted] អាំងនីវ និងកូនប្រសារឈ្មោះ [redacted] សុជា ទៅជីកដីដាំបង្គោលបម្រុងធ្វើរបងលើដីដែលមានម្ចាស់ឈ្មោះ [redacted] ម៉េងទៀង បានព្រមព្រៀងទុកបើកទ្រូងផ្លូវឲ្យឡានដឹកទំនិញរបស់ឈ្មោះ ជា ស្រីនាង ចេញចូលបាននៅចំណុចភូមិព្រែក ឃុំត្រើយស្លា ស្រុកស្អាង ខេត្តកណ្តាល ទើបឈ្មោះ [redacted] សុខយន ជិះម៉ូតូឌុបប្រពន្ធឈ្មោះ [redacted] សារឿន ទៅហាមឃាត់ការជីកដីបន្តទៀត ក៏បានកើតជាទំនាស់ប្រតាយប្រតប់គ្នា បណ្តាលឲ្យឈ្មោះ [redacted] សុខយន និងប្រពន្ធឈ្មោះ [redacted] សារឿន រងរបួស ។

## បានឃើញ

-ដីកាសន្និដ្ឋានស្ថាពរលេខៈ ១០១៦ ដក.សព/១៩ ចុះថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ ២០១៩ របស់អយ្យការអមសាលាដំបូងខេត្តកណ្តាល ។

-ដីកាដំណោះស្រាយលេខៈ ១០៩២ ដកជស ចុះថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ ២០១៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្តាល ។

-ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខៈ ១១៤៣ ដកចត/១៩ ចុះថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ ២០១៩ របស់ប្រធានសាលាដំបូងខេត្តកណ្តាល ។

## នាពេលសវនាការ

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់ចម្លើយសាក្សី

-ក្រោយពីបានស្តាប់ការសន្និដ្ឋានទោសរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានមេធាវីការពារក្តីឲ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់

-ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ

# សំអាងហេតុ

១-កាលពីថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៩ ស្ថិតនៅភូមិព្រៃក ឃុំត្រើយស្លា ស្រុកស្អាង ខេត្តកណ្ដាល ពិតជាកើតមាននូវអំពើ ហិង្សាដោយចេតនា ប្រាកដមែន ដែលអំពើនេះប្រព្រឹត្តឡើងដោយជនជាប់ចោទឈ្មោះ [redacted] សុធីរៈ , ឈ្មោះ [redacted] ប៊ុនណាក់ , ឈ្មោះ [redacted] អាំងនីវ និងឈ្មោះ [redacted] សុផា បានធ្វើសកម្មភាពវាយតបទៅលើជនរងគ្រោះឈ្មោះ [redacted] សុខឃន និងឈ្មោះ [redacted] សារឿន បណ្ដាលឲ្យជនរងគ្រោះរងរបួស ។

២-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **សុធីរៈ** បានឆ្លើយថាៈ នៅថ្ងៃកើតហេតុ ខ្លួនពុំបានវាយទាត់ធាក់ទៅលើជនរងគ្រោះទេ ។ ចំពោះឈ្មោះ [redacted] សារឿន រងរបួសជាំលើភ្នែកខាងឆ្វេងនោះខ្លួនពុំឡើយ ព្រោះពេលកើតហេតុខ្លួនឃើញជនរងគ្រោះពុំមានរងរបួសឡើយ ។ កន្លងមកក្រុមគ្រួសារខ្លួន និងក្រុមគ្រួសារជនរងគ្រោះមិនដែលមានទំនាស់អ្វីទេ ។ តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **ប៊ុនណាក់** បានឆ្លើយថាៈ ខ្លួនពុំបានវាយតបទៅលើឈ្មោះ [redacted] ឃន និងឈ្មោះ [redacted] សារឿន ដូចការចោទប្រកាន់នោះទេ ។ ចំពោះរបួសជាំភ្នែករបស់ជនរងគ្រោះ ខ្លួនពុំបានដឹងឡើយ ព្រោះថ្ងៃកើតហេតុពុំមានអ្នកណាវាយទៅលើជនរងគ្រោះឡើយ ហើយក៏ពុំបានឃើញជនរងគ្រោះមានរបួសដែរ ។ តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **អាំងធីវ** បានឆ្លើយថាៈ នៅថ្ងៃកើតហេតុ ខ្លួនមិនបានទាញ និងរុញច្រានឈ្មោះ [redacted] ឃន និងឈ្មោះ [redacted] សារឿន ទេ ហើយក៏ពុំមានអ្នកណាម្នាក់វាយទៅលើឈ្មោះនេះដែ ។ មូលហេតុដែលនាំឲ្យកើតមានរឿងនេះឡើងដោយក្រុមគ្រួសារខ្លួនបាននាំគ្នាជីកដីដើម្បីដាំបង្គោលធ្វើរបងនៅលើដីខ្លួនប៉ុណ្ណោះ ប៉ុន្តែជនរងគ្រោះបានជិះម៉ូតូមកឈប់កន្លែងដែលខ្លួនកំពុងជីកធ្វើរបងហើយអះអាងថាខ្លួនធ្វើរបងបិទផ្លូវចេញចូលទៅវិញ ។ តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **សុផា** បានឆ្លើយថាៈ ខ្លួនពុំបានវាយតបទៅលើជនរងគ្រោះ ដូចការចោទប្រកាន់នោះទេ គឺគ្រាន់តែបានរុញច្រាននិងឃាត់ជនរងគ្រោះកុំឲ្យមកលុបដី ឬដកបង្គោលថ្មខ្លួន ដែលបានដាំនៅលើដីរបស់ម្ដាយខ្លួនប៉ុណ្ណោះ។ ចំពោះរបួសដែលជាំលើភ្នែកខាងឆ្វេងរបស់ឈ្មោះ [redacted] សារឿន ខ្លួនពុំដឹងថាត្រូវនឹងអ្វីទេ ។ ឃើញថា ចម្លើយនេះជាចម្លើយដោះសារតែប៉ុណ្ណោះពុំមានសាក្សីនិងភស្តុតាងដោះបន្ទុកគ្រប់គ្រាន់ដែលធ្វើឲ្យតុលាការជឿ បានឡើយ ព្រោះថាចម្លើយនេះមានភាពផ្ទុយគ្នាទៅនឹងចម្លើយរបស់ជនរងគ្រោះ របាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ និងភស្តុតាងជារូបថតរងរបួសជនរងគ្រោះ ។

៣-តាមចម្លើយជនរងគ្រោះ និងជាដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សុខឃន** បានបញ្ជាក់ថា៖ នៅថ្ងៃកើតហេតុខ្លួនបានជិះម៉ូតូទៅហាមឃាត់ឈ្មោះ [redacted] សុធីរៈ , ឈ្មោះ [redacted] ប៊ុនណាក់ , ឈ្មោះ [redacted] អាំងនីវ , ឈ្មោះ [redacted] ង សុផា មិនឲ្យជីកដីដាំបង្គោលរបងលើដីខ្លួន ដើម្បីធ្វើផ្លូវសម្រាប់ឲ្យឡានដឹកទំនិញចេញចូល ពេលទៅដល់ខ្លួនឈប់ម៉ូតូឈរនៅមុខរណ្ដៅ និងប្រឡាយរៀបធ្វើរបងថ្ម ភ្លាមនោះឈ្មោះខាងលើមិនព្រមស្ដាប់ ថែមទាំងរុញខ្លួន និងម៉ូតូខ្លួនដួលទៅសង្កត់ពីលើខ្លួន បន្ទាប់មកអ្នកទាំងបួនបាននាំគ្នាលើកអូសម៉ូតូខ្លួន និងអូសខ្លួនចេញពីកន្លែងរណ្ដៅ បណ្ដាលឲ្យខ្លួនរងរបួសជាំខ្នង ឯប្រពន្ធខ្លួនជាំភ្នែក ។ តាមចម្លើយជនរងគ្រោះ និងជាដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សារឿន** បានបញ្ជាក់ថា៖ នៅថ្ងៃកើតហេតុ មានឈ្មោះ [redacted] ព្រួញ និងឈ្មោះ [redacted] អាំងធីវ បានវាយទាត់ធាក់មកលើខ្លួនបណ្ដាលឲ្យរងរបួសជាំភ្នែកខាងឆ្វេង និងចំឆ្អឹងខ្នង ហើយឈ្មោះ [redacted] ព្រួញ បានទាត់ខ្លួនចំនួន ០២ ជើងចំខ្នងបណ្ដាលឲ្យដួល និងឈ្មោះ [redacted] អាំងធីវ ទាត់ខ្លួនចំនួន ០១ ជង្គង់ និងកែងចំមុខ តែខ្លួនយកដៃរងបណ្ដាលឲ្យហើមមុខ និងវង្វេងវង្វាន់ ។ ឃើញថា ចម្លើយនេះអាចឲ្យតុលាការជឿបាន ព្រោះថាចម្លើយនេះមានភាពស៊ីសង្វាក់ទៅនឹងចម្លើយសាក្សី របាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ និងរូបថតរងរបួសរបស់ជនរងគ្រោះ ។



Scanned with CamScanner

៤-តាមចម្លើយសាក្សីឈ្មោះ[redacted]**សាងអែ** បានឆ្លើយថា៖ ខ្លួនត្រូវជាក្មួយបង្កើតរបស់ឈ្មោះ[redacted]ព្រីង។ ខ្លួនពុំបានដឹងថាឈ្មោះ [redacted] សារឿន រងរបួសភ្នែកខាងឆ្វេងជាំនោះទេ ព្រោះពេលកើតហេតុ ពុំមានអ្នកណាវាយទៅលើគាត់នោះទេ ព្រោះខ្លួនក៏បានចូលទៅជួយចាប់ឃាត់គាត់ដែរ ។ ពេលកើតហេតុភ្លាមៗខ្លួនពុំបានឃើញឈ្មោះ [redacted] សារឿន រងរបួសជាំភ្នែកនោះទេ ។

-តាមចម្លើយរបស់សាក្សីឈ្មោះ[redacted]**អ៊ឹងហេង** បានឆ្លើយថា៖ ខ្លួនមិនបានឃើញក្មួយខ្លួនឈ្មោះ [redacted] សុធីរៈ ,ឈ្មោះ[redacted]ប៊ុនណាក់ ,ឈ្មោះ[redacted]អាំងនីវ និងឈ្មោះ[redacted]សុជា វាយទៅលើឈ្មោះ[redacted] សុខយន និងប្រពន្ធឈ្មោះ[redacted] សារឿន នោះទេ ។ ចំពោះ[redacted]សារឿន រងរបួសជាំភ្នែកខាងឆ្វេងខ្លួនពុំដឹងអ្នកណាវាយទេ។ ខ្លួនឃើញក្មួយខ្លួនទាំងបួនខាងលើពិតជាបានប្រតាយប្រតប់គ្នាជាមួយឈ្មោះ[redacted]សុខយន និងប្រពន្ធឈ្មោះ[redacted] សារឿន ពិតមែន ព្រោះពេលនោះខ្លួនក៏បានចូលឃាត់ដែរ ។

-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ[redacted]**ចាក់** បានឆ្លើយថា៖ នៅថ្ងៃកើតហេតុពុំដឹងអ្នកណាវាយទៅលើឈ្មោះ [redacted]សុខយន និងប្រពន្ធឈ្មោះ [redacted]សារឿន ដូចការចោទប្រកាន់នោះទេ ព្រោះពេលនោះខ្លួនក៏ជួយឃាត់ភាគីខាងគាត់ដែរ ហើយខ្លួនឃើញកូនឈ្មោះ [redacted]សុខយន ជាអ្នកវាយបងស្រីខ្លួនឈ្មោះ [redacted]ព្រីង មួយដៃនៅពីក្រោយបណ្តាលឲ្យសន្លប់ ។

-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ[redacted] **ព្រីង** បានឆ្លើយថា៖ នៅថ្ងៃកើតហេតុកូនខ្លួនមិនបានវាយទៅលើឈ្មោះ[redacted]សុខយន និងប្រពន្ធឈ្មោះ [redacted] សារឿន នោះទេ ព្រោះខ្លួនក៏បានទៅឃាត់ដែរ ក្រោយមកបន្ទាប់ពីលោកមេប៉ុស្តិ៍ និង មេប៉ុស្តិ៍រងមកដល់ កំពុងតែពិនិត្យមើល ស្រាប់តែមានកូនរបស់ឈ្មោះ អាន សុខយន ស្ទុះមកវាយខ្លួនពីក្រោយមួយដៃចំខ្នងបណ្តាលឲ្យដួលសន្លប់នៅមុខមេប៉ុស្តិ៍តែម្តង ។

-តាមចម្លើយរបស់សាក្សីឈ្មោះ[redacted]**ភារ៉ា** បានឆ្លើយថា៖ ខ្លួនពិតជាមិនបានឃើញសកម្មភាពអ្នកណាវាយឪពុកម្តាយរបស់ខ្លួននោះទេ ប៉ុន្តែខ្លួនដឹងថាពួកគាត់បានមានទំនាស់ជាមួយគ្រួសាររបស់ឈ្មោះ គ្រី ព្រីង ហើយខ្លួនក៏ឃើញឈ្មោះ[redacted]សុធីរៈ និងម្តាយខ្លួនប្រតាយប្រតប់គ្នាបន្តិចបន្តួចប៉ុណ្ណោះ តែរបួសម្តាយខ្លួន ជាត្រង់ភ្នែកខាងឆ្វេង ហើយពុំដឹងថាអ្នកណាវាយត្រូវគាត់ឡើយ ។ ចំពោះឪពុកខ្លួនគាត់រងរបួសជាំពេញខ្លួន ដោយសារត្រូវខាងគេរុញច្រាន និងអូសទាញគាត់ចេញពីរណ្តៅដែលគេជីក ។

-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] **ថុងហាក់** បានឆ្លើយថា៖ នៅថ្ងៃកើតហេតុ ខ្លួនពុំទាន់គេប្រតាយប្រតប់គ្នានោះទេ ដោយទៅដល់ក៏ឃើញឈ្មោះ[redacted]សារឿន រងរបួសជាំភ្នែក និងហើមមុខបាត់ហើយ ដោយពុំដឹងអ្នកណាវាយគាត់នោះទេ ។ ប៉ុន្តែនៅកន្លែងកើតហេតុមានឃើញឈ្មោះ[redacted] សុធីរៈ ,ឈ្មោះ[redacted]ប៊ុនណាក់ ,ឈ្មោះ [redacted]អាំងនីវ និងឈ្មោះ [redacted] សុជា នៅទីនោះប្រាកដមែន ហើយបានស្រែកជេរទៅវិញទៅមកជាមួយគ្រួសារឈ្មោះ[redacted]សុខយន ។

-តាមចម្លើយរបស់សាក្សីឈ្មោះ[redacted]**ម៉េងទៀត** បានឆ្លើយថា៖ ពេលកើតហេតុខ្លួនឃើញឈ្មោះ[redacted] សុខយន និងប្រពន្ធឈ្មោះ [redacted]សារឿន បានជិះម៉ូតូឌុបគ្នាមកឈប់នៅលើរណ្តៅដែលឈ្មោះ ជី សុធីរៈ , ឈ្មោះ[redacted]ប៊ុនណាក់ ,ឈ្មោះ[redacted] អាំងនីវ និងបក្សពួកបួននាក់ទៀតមិនស្គាល់ឈ្មោះ កំពុងជីករណ្តៅដាំបង្គោលរបងនៅលើដីដែលខ្លួនលក់ឲ្យ ទំហំ ២,៥០ x ២២ ម៉ែត្រ ហើយអ្នកទាំងបីបានរុញឈ្មោះ អាន សុខយន និងប្រពន្ធឈ្មោះ [redacted] សារឿន ចេញពីរណ្តៅ តែជនរងគ្រោះមិនព្រមចេញ ក៏បងប្អូនកូនក្មួយរបស់ឈ្មោះ យាយព្រីង នាំគ្នាទៅសែងម៉ូតូ និងឈ្មោះ យន និងប្រពន្ធចេញតែម្តង ដែលពុំបានវាយតប់គ្នាទេ ។ ខ្លួនឃើញឈ្មោះ រឿន និង នីវ កំពុងប្រតាយប្រតប់គ្នាបោចសក់ក្បាល ហើយក៏មានអ្នកស្រុកចូលទៅជួយឃាត់ចាប់បំបែកចេញ ហើយក៏មិនដឹងថាឈ្មោះ រឿន ត្រូវគេវាយឬអត់ទេ ។



Scanned with CamScanner

-តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] កាណាន់ បានឆ្លើយថា៖ នៅថ្ងៃកើតហេតុខ្លួនបានចូលចាប់ឃាត់ឈ្មោះ [redacted] សុខឃន និងលើកម៉ូតូចេញពីរណ្តៅ បន្ទាប់មកខ្លួនក៏ទៅឈរមើលនៅកន្លែងរបង ដោយមានឈ្មោះ [redacted] សុធីរៈ ,ឈ្មោះ [redacted] ប៊ុនណាក់ ,ឈ្មោះ [redacted] អាំងធីវ នៅឈរការពាររណ្តៅកុំឲ្យឈ្មោះ [redacted] សុខឃន និងប្រពន្ធចូលមកក្នុងរណ្តៅដែរ ។ ខ្លួនពុំបានឃើញឈ្មោះ [redacted] អាំងនីវ ,ឈ្មោះ [redacted] ប៊ុនណាក់ ,ឈ្មោះ [redacted] សុធីរៈ វាយតប់ទៅឈ្មោះ [redacted] សុខឃន និងប្រពន្ធនោះទេ គ្រាន់តែចាប់រុញជនរងគ្រោះកុំឲ្យលុបរណ្តៅដែលពួកខ្លួនជីកប៉ុណ្ណោះ ។ ចំពោះរងរបួសជាំភ្នែកលើជនរងគ្រោះ ខ្លួនពុំបានដឹងថាត្រូវនឹងអ្វីទេ ។

ឃើញថា ចម្លើយសាក្សីទាំងអស់ មានខ្លះឆ្លើយដាក់បន្ទុកលើជនជាប់ចោទ ហើយខ្លះឆ្លើយដោះបន្ទុកលើជនជាប់ចោទ តែចម្លើយសាក្សីដោះបន្ទុក គប្បីពុំអាចជឿរបានឡើយ ព្រោះថាចម្លើយនេះមានភាពផ្ទុយគ្នាទៅនឹងរូបថតរងរបួសរបស់ជនរងគ្រោះ ឯចម្លើយសាក្សីដាក់បន្ទុក ជាចម្លើយដែលអាចជឿរបាន ព្រោះថាចម្លើយនេះមានភាពស៊ីសង្វាក់ទៅនឹងរូបថតរងរបួសរបស់ជនរងគ្រោះ ។

៥-ទាំងចម្លើយជនជាប់ចោទ , ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ចម្លើយសាក្សី និងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងភស្តុតាងឯកសារ មានភាពស៊ីសង្វាក់គ្នាដែលកំណត់បានថា ជនជាប់ចោទពិតជាបានប្រព្រឹត្តបទល្មើសប្រាកដមែន។

៦-មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ដែលបញ្ជាក់ថា ជនជាប់ចោទពិតជាបានប្រព្រឹត្តបទល្មើស ប្រាកដមែន។

៧-អំពើរបស់ជនជាប់ចោទបានស្តែងឡើងដោយ មានចេតនាវាយតបទៅលើជនរងគ្រោះ បណ្តាលឲ្យជនរងគ្រោះរងរបួស ដែលអំពើនេះច្បាប់កំណត់ថាជាបទល្មើសព្រហ្មទណ្ឌ និងមានចែងក្នុងមាត្រា ១២៧ ក្រមព្រហ្មទណ្ឌ។

៨-ជនជាប់ចោទជានីតិជន បានប្រព្រឹត្តបទល្មើសដោយមានចេតនា និងការយល់ដឹងពីអំពើរបស់ខ្លួនដូច្នេះជនទាំងនេះត្រូវទទួលខុសត្រូវនូវទង្វើដែលខ្លួនបានប្រព្រឹត្តចំពោះច្បាប់ ។

៩-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] **សុធីរៈ** , ឈ្មោះ [redacted] **ប៊ុនណាក់** , ឈ្មោះ [redacted] **អាំងនីវ** និងឈ្មោះ [redacted] **សុជា** ដែលមានសាវតាដូចខាងលើ ពីបទៈ **ហិង្សាដោយចេតនា** ប្រព្រឹត្តនៅភូមិព្រៃក ឃុំត្រើយស្លា ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២១៧ នៃក្រមព្រហ្មទណ្ឌ។

១០-គប្បីតុលាការប្រកាសទណ្ឌកម្មលើជនជាប់ចោទក្នុងកំរិតដាក់ពន្ធនាគារ ១ឆ្នាំ ដោយពិចារណាទៅលើលើភាពធ្ងន់ស្រាលនៃបទល្មើស និងសកម្មភាពល្មើសរបស់ជនជាប់ចោទដូចខាងក្រោមៈ

+អំពើល្មើសរបស់ជនជាប់ចោទបានធ្វើឲ្យប៉ះពាល់ដល់ រូបរាងកាយរបស់អ្នកដទៃ សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយសង្គម។

+សកម្មភាពល្មើសពុំបង្កឲ្យមានព្យសនៈកម្មធ្ងន់ធ្ងរឡើយ ។ មូលហេតុទាំងនេះហើយនាំឲ្យតុលាការ ពិចារណាប្រកាសទោសក្នុងកំរិតខាងលើដល់ជនជាប់ចោទ ។

១១-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សុខឃន** បានប្តឹងទាមទារសំណងជម្ងឺចិត្តចំនួន ៥០.០០០ (ប្រាំម៉ឺន)ដុល្លារអាមេរិក និងថ្លៃឡានខូចមិនបានរកស៊ីព្រោះបិទផ្លូវមិនឲ្យឡានចេញចូលចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក ឃើញថា បណ្តឹងនេះធ្វើឡើងមានលក្ខណៈត្រឹមត្រូវតាមមាត្រា១៣ , មាត្រា១៤ , មាត្រា១៥ , មាត្រា២១ និងមាត្រា២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលតុលាការអាចពិនិត្យនិងសម្រេចបានតាមមាត្រា២៤ នៃក្រមនីតិវិធី ព្រហ្មទណ្ឌ ។ តាមការពិនិត្យឃើញថា ការទាមទាររបស់ដើមបណ្តឹងរដ្ឋប្បវេណីមានចំនួនច្រើនដែលគប្បីតុលាការបន្ទូបន្ថយឲ្យបានសមស្របទៅនឹងទំហំព្យសនៈកម្មជាក់ស្តែង។



Scanned with CamScanner

១២-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំៈ ឆ្លងកាត់តាមការសួរដេញដោលនាពេលសវនាការ ឃើញថា ពិតជាកើតមាននូវអង្គហេតុនៃអំពើ ហិង្សាដោយចេតនា ប្រាកដមែន ។ ឃើញថា មានភស្តុតាងនិង សាក្សីដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទ ។ រក្សាបទចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខៈ ១០១៦ ដក.សព/១៩ ចុះថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ ២០១៩ របស់អយ្យការអមសាលាដំបូងខេត្តកណ្តាល ។ ស្នើសុំឲ្យ តុលាការសម្រេចតាមច្បាប់ ។ តុលាការយល់ស្របចំពោះសេចក្តីសន្និដ្ឋាននេះ ។

១៣-មេធាវីការពារក្តីឲ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានៈ ក្រោយពីបានសួរដេញដោលនាពេល សវនាការ ឃើញថា ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី មានការប្រែប្រួល មិនមានភាពស៊ីសង្វាក់ទៅនឹងអង្គ ហេតុ គឺជាចម្លើយប្រឌិត ។ តាមចម្លើយសាក្សី គឺគ្មាននរណាម្នាក់ដឹងថាមានការវាយប្រតាយប្រតបគ្នាទេ ហើយជនរងគ្រោះក៏មិនបានដឹងថានរណាវាយខ្លួនដែ ។ ដូច្នេះរឿងហេតុនេះគឺជាវិមតិសង្ស័យតែប៉ុណ្ណោះ ដោយយោងតាមមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា វិមតិសង្ស័យត្រូវជាប្រយោជន៍ដល់ជនជាប់ ចោទ ។ ស្នើរសុំតុលាការឲ្យជនជាប់ចោទរួចខ្លួនពីបទចោទប្រកាន់ ។ តុលាការឃើញថាសេចក្តីសន្និដ្ឋាននេះ មានលក្ខណៈត្រឹមត្រូវមួយចំនួនពាក់ព័ន្ធទៅនឹងអង្គហេតុនិងអង្គច្បាប់ តែការស្នើរសុំឲ្យជនជាប់ចោទរួចខ្លួនពី បទចោទប្រកាន់នោះ ឃើញថា ពុំមានសំអាងហេតុគ្រប់គ្រាន់ក្នុងការដោះបន្ទុកឡើយ ។

## **សម្រេច**

១.ផ្តន្ទាទោសលើៈ

១/១.ឈ្មោះ [redacted] **សុធីរៈ** ហៅ **ព្រួញ** ភេទប្រុស អាយុ ៣០ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ កសិករ ទីកន្លែង កំណើត និងទីលំនៅបច្ចុប្បន្ននៅភូ[redacted]ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] ជី (រ) ម្តាយ ឈ្មោះ [redacted] ព្រីង (រ) ប្រពន្ធឈ្មោះ[redacted]សេរីវ័ត្ន មានកូន ០១ នាក់ ទោសពីមុន គ្មាន ។ (ក្រៅឃុំ)

១/២.ឈ្មោះ[redacted]**ប៊ុនណាក់** ភេទប្រុស អាយុ ៣៤ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ បុគ្គលិកក្រុមហ៊ុនឯកជន ទី កន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិ[redacted]ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] ជី (រ) ម្តាយឈ្មោះ[redacted]ព្រីង (រ) ប្រពន្ធឈ្មោះ [redacted]ការី មានកូន ០២ នាក់ ទោសពីមុន គ្មាន ។ (ក្រៅឃុំ)

១/៣.ឈ្មោះ[redacted] **អាំងនីវ** ភេទស្រី អាយុ ៣៧ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ កសិករ ទីកន្លែងកំណើត និងទី លំនៅបច្ចុប្បន្ននៅភូមិ[redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted]ជី (រ) ម្តាយឈ្មោះ[redacted]ព្រីង (រ) ប្តីឈ្មោះ[redacted]សុជា មានកូន ០២ នាក់ ទោសពីមុន គ្មាន ។ (ក្រៅឃុំ)

១/៤.ឈ្មោះ[redacted] **សុជា** ហៅ ទូច ភេទប្រុស អាយុ ៣៧ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ កសិករ ទីកន្លែង កំណើតនៅភូមិ[redacted]ខេត្តកណ្តាល និងទីលំនៅបច្ចុប្បន្ននៅភូមិ[redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted]ខង (រ) ម្តាយឈ្មោះ [redacted] សុខគន (រ) ប្រពន្ធឈ្មោះ[redacted]អាំងនីវ មានកូន ០២ នាក់ ទោសពីមុន គ្មាន ។ (ក្រៅឃុំ)

ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេល ១(មួយ)ឆ្នាំ តែទោសនេះត្រូវអនុវត្តទោសព្យួរធម្មតា ពីបទៈ **ហិង្សាដោយចេតនា** ប្រព្រឹត្តនៅភូមិព្រែក ឃុំត្រើយស្លា ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី០៩ ខែមីនា ឆ្នាំ ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២១៧ នៃក្រមព្រហ្មទណ្ឌ។

២.បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] **សុធីរៈ** ,ឈ្មោះ [redacted] **ប៊ុនណាក់** ,ឈ្មោះ [redacted]**អាំងនីវ** និងឈ្មោះ [redacted] **សុជា** ដែលមានសាវតាដូចខាងលើ រួមគ្នាសងសំណងជម្ងឺចិត្តជាប្រាក់ចំនួន ២.០០០.០០០ (ពីរលាន) រៀល ទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]សុខឃន សំណើរលើសពីនេះបដិសេធចោល ។



Scanned with CamScanner

សាលក្រមនេះប្រកាសជាសាធារណៈ នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវប្តឹងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខា និងត្រា៖ [redacted]

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និងត្រា៖ [redacted]

---

បានឃើញ
**ចៅក្រមជំនុំជម្រះ**

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃព្រហស្បតិ៍ ៥រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
ធ្វើនៅកណ្តាល, ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០
**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner